មជ្ឈមណ្ឌលសហប្រតិបត្តិការកម្ពុជា-ជប៉ុន(CJCC)
កម្មវិធីធំនាក់ធំនងវប្បធម៌

# សេចក្តីជូនដំណឹង



មជ្ឈមណ្ឌលសហប្រតិបត្តិការកម្ពុជា-ជប៉ុន សូមជម្រាបជូនដំណឹងដល់សាធារណជនអោយបានជ្រាបថា ដោយមានកិច្ចសហការជាមួយសមាគមជនជាតិជប៉ុននៅកម្ពុជា មជ្ឈមណ្ឌលកំពុងរៀបចំ**ពិធីបុណ្យរបាំប្រជាប្រិយជប៉ុន (Bon Odori)** ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី១៨ ខែតុលា ឆ្នាំ២០០៩ ចាប់ពីម៉ោង ៥:00 ដល់ម៉ោង ៨:00 ល្ងាច នៅក្នុងបរិវេណមជ្ឈមណ្ឌលសហប្រតិបត្តិការកម្ពុជា-ជប៉ុន។

ដើម្បីអោយមានភាពងាយស្រួលក្នុងការរាំរបាំប្រជាប្រិយខ្មែរនិងជប៉ុននៅថ្ងៃប្រារព្ធពិធី មជ្ឈមណ្ឌលនឹងធ្វើការហ្វឹកហាត់ដោយឥតគិតថ្លៃសម្រាប់និស្សិតស្ម័គ្រចិត្តមួយចំនួន តាមកាលវិភាគហ្វឹកហាត់ដូចខាងក្រោម។ ក្រោយបញ្ចប់ការហ្វឹកហាត់ នៅថ្ងៃទី១០ ខែតុលា ឆ្នាំ២០០៩ មជ្ឈមណ្ឌលនឹងធ្វើការជ្រើសរើសនិស្សិតដែលមានទេពកោសល្យរាំចង្វាក់ប្រជាប្រិយខ្មែរនិងជប៉ុនបានល្អ ចំនួន៤០នាក់ (បុរស២០នាក់ និងនារី២០នាក់) ដើម្បីចូលរួមក្នុងក្រុមរាំគំរូនៅក្នុងកម្មវិធីបុណ្យរបាំប្រជាប្រិយជប៉ុន។

**កាលវិភាគហ្វឹកហាត់**

| **កាលបរិច្ឆេទ** | **ម៉ោង** | **ទីកន្លែង** |
|---|---|---|
| ថ្ងៃសៅរ៍ ទី២៩ ខែសីហា ឆ្នាំ២០០៩ | ១៤:00-១៥:00 (របាំខ្មែរ) និង ១៥:00-១៦:00 (របាំជប៉ុន) | កន្លែងទទួលភ្ញៀវ **CJCC** |
| ថ្ងៃសៅរ៍ ទី៥ ខែកញ្ញា ឆ្នាំ២០០៩ | ១៤:00-១៥:00 (របាំខ្មែរ) និង ១៥:00-១៦:00 (របាំជប៉ុន) | កន្លែងទទួលភ្ញៀវ **CJCC** |
| ថ្ងៃសៅរ៍ ទី១២ ខែកញ្ញា ឆ្នាំ២០០៩ | ១៤:00-១៥:00 (របាំខ្មែរ) និង ១៥:00-១៦:00 (របាំជប៉ុន) | កន្លែងទទួលភ្ញៀវ **CJCC** |
| ថ្ងៃសៅរ៍ ទី២៦ ខែកញ្ញា ឆ្នាំ២០០៩ | ១៤:00-១៥:00 (របាំខ្មែរ) និង ១៥:00-១៦:00 (របាំជប៉ុន) | កន្លែងទទួលភ្ញៀវ **CJCC** |
| ថ្ងៃសៅរ៍ ទី១០ ខែតុលា ឆ្នាំ២០០៩ | ១៤:00-១៥:00 (ការជ្រើសរើសអ្នករាំនាំមុខរបាំ)<br>១៥:00-១៦:00 (ការហាត់ស្នៀកសំលៀកបំពាក់ជប៉ុន) | កន្លែងទទួលភ្ញៀវ **CJCC** |

**១. ល័ក្ខខ័ណ្ឌចុះឈ្មោះជានិស្សិតស្ម័គ្រចិត្ត :**

- ជាពលរដ្ឋកម្ពុជា
- និស្សិតមហាវិទ្យាល័យ ឬ សាកលវិទ្យាល័យ
- តំរូវអោយលោកអ្នកជួយបង្រៀនជនជាតិជប៉ុនរាំចង្វាក់ប្រជាប្រិយខ្មែរដូចជា រាំវង់ រាំក្បាច់ និង សារ៉ាវ៉ាន់។ ដូច្នេះលោកអ្នកគួរតែជាអ្នកយល់ដឹងពីវប្បធម៌ខ្មែរ ជាពិសេសផ្នែករបាំប្រជាប្រិយ
- ផ្តល់អាទិភាពចំពោះនិស្សិតដែលធ្លាប់ស្ម័គ្រចិត្តចូលរួមកាលពីឆ្នាំមុនៗ។

**២. អត្ថប្រយោជន៍សំរាប់និស្សិតស្ម័គ្រចិត្ត :**

- លោកអ្នកនឹងមានឱកាសទទួលបាននូវបទពិសោធន៍ដែលទាក់ទងនឹងវប្បធម៌ជប៉ុន និងអាចមានចំណងមិត្តភាពជាមួយជនជាតិជប៉ុន និងជនជាតិដទៃផ្សេងទៀត។
- ទទួលបានសំបុត្រចូលរួមពិធីមួយសន្លឹក អាហារ និងការស្លៀកសំលៀកបំពាក់ជប៉ុនដោយឥតគិតថ្លៃ។

**✻ សូមទាក់ទងចុះឈ្មោះនៅកន្លែងផ្តល់ព័ត៌មានរបស់មជ្ឈមណ្ឌលសហប្រតិបត្តិការកម្ពុជា-ជប៉ុនចាប់ពីពេលផ្សាយដំណឹងនេះតទៅ ។**

មជ្ឈមណ្ឌលសហប្រតិបត្តិការកម្ពុជា-ជប៉ុន: ស្ថិតនៅក្នុងបរិវេណវិទ្យាស្ថានភាសាបរទេស(IFL) មហាវិថីសហព័ន្ធរុស្ស៊ី
ខណ្ឌទួលគោក រាជធានីភ្នំពេញ។ ទូរស័ព្ទ: 023 880 552 & Email: ep@cjcc.edu.kh ។